អង្គការអភិវឌ្ឍន៍សំលេងសហគមន៍

**គម្រោង៖** បង្កើនជីវភាពរស់នៅរបស់សហគមន៍ តាមរយៈអេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ

# របាយការណ៍ករណីសិក្សា

## សហគមន៍អេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ – ប្រធានគណៈកម្មការសហគមន៍

១. សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្ម ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយមានការគាំទ្រពីមន្ទីរ និងក្រសួងបរិស្ថាន។ សហគមន៍មានផ្ទៃដី ៥០៦ ហិកតា មានគណៈកម្មការ ៩ រូប (ស្រី ៣ រូប) និងមានអ្នកទទួលផលសរុប ៦២៥ នាក់។ ប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ចិញ្ចឹមសត្វ និងប្រមូលអនុផលព្រៃឈើ ខណៈមួយចំនួនធ្វើការចំណាកស្រុក។

សហគមន៍កំពុងប្រឈមមុខនឹងបញ្ហាខ្វះធនធានថវិកា ដៃគូអភិវឌ្ឍន៍ និងសមត្ថភាពបច្ចេកទេស។ បន្ថែមពីនេះ ភូមិជីពូក និងភូមិងយ រងផលប៉ះពាល់ពីរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់ទិន្នផលកសិកម្ម និងជីវភាពរស់នៅ បង្កើនហានិភ័យនៃសកម្មភាពខុសច្បាប់លើធនធានធម្មជាតិ។

## ២. ព័ត៌មានទូទៅអំពីលោក ស្វាយ ណឹម ប្រធានគណៈកម្មការសហគមន៍ព្រៃធំអន្លង់ថ្ម

លោក ស្វាយ ណឹម អាយុ ៥២ ឆ្នាំ រស់នៅភូមិជីពូក ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ លោកមានមុខរបរជាកសិករ និងបានក្លាយជាប្រធានគណៈកម្មការសហគមន៍ព្រៃធំអន្លង់ថ្ម តាំងពីឆ្នាំ ២០០៥ តាមរយៈការបោះឆ្នោតពីប្រជាពលរដ្ឋក្នុងសហគមន៍។ មូលហេតុដែលលោកសម្រេចចិត្តចូលរួមជាគណៈកម្មការ គឺដោយសារតែលោកស្រឡាញ់បរិស្ថាន ចង់ការពារ និងអភិរក្សព្រៃឈើ ធនធានធម្មជាតិ និងសត្វព្រៃឱ្យបានគង់វង្ស។ លើសពីនេះ លោកមានគោលបំណងទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកទស្សនាធនធានធម្មជាតិនៅក្នុងព្រៃសហគមន៍ ដើម្បីបង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ។ ទោះបីជាលោកមានតួនាទីជាប្រធានគណៈកម្មការក៏ដោយ មុនពេលទទួលបានការគាំទ្រពីគម្រោង GEF លោកមិន

ទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងដឹកនាំសមាជិកគណៈកម្មការ។ លោកខ្វះជំនាញក្នុងការដឹកនាំ ការសរសេររបាយការណ៍ ការរៀបចំ គ្រប់គ្រងឯកសារ ការធ្វើផែនការសកម្មភាព និងការចងក្រងក្រុមសហគមន៍។



### ៣. ឆ្នាំ ២០២៤ សហគមន៍ព្រៃធំអន្លង់ថ្ម ទទួលបានការគាំទ្រពីគម្រោង GEF

នៅឆ្នាំ ២០២៤ សហគមន៍ព្រៃធំអន្លង់ថ្ម បានទទួលការគាំទ្រពីគម្រោង GEF ដែលជាឱកាសដ៏ល្អសម្រាប់លោកក្នុងការពង្រឹងសមត្ថភាព និងជំនាញ ដូចជា ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ការសរសេររបាយការណ៍ និងការធ្វើផែនការសកម្មភាព។ ជាពិសេស លោកបានចូលរួមទស្សនកិច្ចសិក្សានៅសហគមន៍ផ្សេងៗដែលមានសកម្មភាពស្រដៀងគ្នា ដើម្បីដកស្រង់បទពិសោធន៍។ ក្រៅពីការបណ្តុះបណ្តាល លោក និងសមាជិកគណៈកម្មការ បានអនុវត្តសកម្មភាពយ៉ាងសកម្ម ដូចជា៖ រៀបចំកិច្ចប្រជុំជាប្រចាំ (ខ្វះ

រៀងរាល់ ១ ខែ និងខ្លះរៀងរាល់ ៣ ខែ) ចុះល្បាត និងទប់ស្កាត់បទល្មើសកាប់ឈើ ដឹកជញ្ជូនឈើ បរបាញ់ និងដាក់អន្ទាក់សត្វ ដាំកូនឈើឡើងវិញ និងធ្វើផ្លូវការពារភ្លើងឆេះព្រៃ បង្កើត និងកែលម្អផ្លូវសម្រាប់ភ្ញៀវទេសចរដើរ និងជិះកង់ទស្សនាព្រៃ ផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ និងសារៈប្រយោជន៍នៃការអភិរក្សធនធានធម្មជាតិ និងពង្រឹងគម្រោងខ្នាតតូចប្រាក់កម្ចីតាមរយៈក្រុមសន្សំប្រាក់សហគមន៍។






## ៤. ការប្រែប្រួល និងការរីកចម្រើនដែលលោក ស្វាយ ណឹម ទទួលបានពីការគាំទ្រគម្រោង GEF

តាមរយៈការកសាងសមត្ថភាពពីគម្រោង GEF លោក ស្វាយ ណឹម មានការអភិវឌ្ឍសមត្ថភាពគួរឱ្យកត់សម្គាល់។ លោកមានទំនុកចិត្ត និងសមត្ថភាពកាន់តែប្រសើរក្នុងការគ្រប់គ្រង និងដឹកនាំសមាជិក គណៈកម្មការ អាចសរសេររបាយការណ៍វឌ្ឍនភាព និងរៀបចំសំណើគម្រោងបានល្អជាងមុន។ ក្រោមការដឹកនាំរបស់លោក សហគមន៍មានការរីកចម្រើនជាក់ស្តែង ដូចជា៖ បានបង្កើតក្រុមសន្សំប្រាក់ មានទី ស្នា

ក់ការសហគមន៍ សាងសង់បន្ទប់ទឹកសម្រាប់ភ្ញៀវ មានសម្ភារៈសម្រាប់ចុះល្បាត បង្កើនជំនាញកសិកម្ម និងការធ្វើជីធម្មជាតិ។

## សម្រង់សម្តីលោក ស្វាយ ណឹម ប្រធានគណៈកម្មការសហគមន៍ព្រៃជំអន្លង់ថ្ម

"ការគាំទ្រពីគម្រោង GEF បានជួយពង្រឹងសមត្ថភាពខ្ញុំយ៉ាងច្បាស់លាស់ ទាំងផ្នែកដឹកនាំ ការគ្រប់គ្រង និងការធ្វើផែនការ។ ខ្ញុំមានទំនុកចិត្តកាន់តែខ្លាំងក្នុងការដឹកនាំសហគមន៍ និងជំរុញសមាជិកឱ្យចូលរួមការពារ និងអភិរក្សព្រៃឈើ។ ខ្ញុំមានមោទនភាពដែលបានឃើញសហគមន៍យើងមានការរីកចម្រើន និងមានចក្ខុវិស័យច្បាស់លាស់សម្រាប់អនាគត"

## សំណូមពរ និងអនុសាសន៍

ក្នុងផែនការបន្ទាប់ លោកមានបំណង សាងសង់កញ្ចុះ អាហារដ្ឋាន និងផ្ទះស្នាក់សម្រាប់ភ្ញៀវ សាងសង់ស្ពានឆ្លងស្ទឹងទៅតំបន់ទេសចរណ៍ជាប់គ្នា ធ្វើទំនប់បង្ហៀរទឹក ដាំដំណាំចម្រុះ (ជំឡូង ម្ទេស ល្ហុង ម្នាស់ ជាដើម) ដើម្បីលម្អសហគមន៍ និងបង្កើនប្រាក់ចំណូល លោកបានសំណូមពរឱ្យអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ បន្តការគាំទ្រផ្នែកធនធានមនុស្ស ថវិកា ជំនាញ និងបច្ចេកទេស ដើម្បីឱ្យសហគមន៍អាចសម្រេចផែនការអភិវឌ្ឍរបស់ខ្លួនបានជោគជ័យ។

**រៀបចំដោយៈ លោកស្រី ជួប ចន្ទី** ក្រុមអ្នកវាយតម្លៃឯករាជ្យ ART